**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១.ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-ទទួលភារកិច្ចជាប្រធានស្ដីទីព្រឹទ្ធសភា

-អញ្ជើញនាំយកបច្ច័យ ទេយ្យវត្ថុ ព្រមទាំងគ្រឿងឧបភោគ បរិភោគ ប្រគេនសម្ដេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត សម្ដេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តបទុមវត្តី ក្នុងខណ្ឌដូនពេញ និងប្រគេនសម្ដេចព្រះវនរ័ត ណយ ច្រឹក សម្ដេចព្រះសង្ឃនាយករងទី៣ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តច័ន្ទបូរីវង្ស ក្នុងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខ័ន្ធសពលោកព្រឹទ្ធាចារ្យ ពោន ពន្ធី អតីតអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅគេហដ្ឋានសព ក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបូជាសពលោកព្រឹទ្ធាចារ្យ ពោន ពន្ធី ក្រោមអធិបតីភាពសម្ដេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បាននាំយកនូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសេនាជូនជាកិច្ចបច្ឆាមរណៈ បំពាក់ជូនដល់សព

-អញ្ជើញចុះការងារមូលដ្ឋានចំនួន០៣លើក ជួបសំណេះសំណាលជាមួយអាជ្ញាធរខណ្ឌព្រែកព្នៅ និងខណ្ឌពោធិ៍-សែនជ័យ ដើម្បីស្វែងយល់ពីសភាពការណ៍នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលដោយផ្ដោតលើសភាពការណ៍សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន និងបាន



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ដោះស្រាយផ្តល់ថវិកា និងផ្តល់អនុសាសន៍ដោះស្រាយការងារបញ្ហាប្រឈមមួយចំនួន នៅក្នុងមូលដ្ឋាននៃខណ្ឌទាំង២ និងបានអញ្ជើញចុះពិនិត្យការដ្ឋានជួសជុលផ្លូវលេខ១៩១ ក្នុងខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១១២ច្បាប់។

**១.២.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** :

-អញ្ជើញជាអធិបតីថ្ងៃសុន្ទរកថាបិទសន្និសីទស្តីពី "ទស្សនភូមិសាស្ត្រនយោបាយតំបន់ និងវិស័យការទូតសភា"

-អញ្ជើញជាអធិបតីថ្ងៃសុន្ទរកថាបើកសិក្ខាសាលាស្តីពី " ការវិវឌ្ឍនៃការអនុវត្តអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ "

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន ៧៦ច្បាប់។

**២. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកុម្ភៈនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាម តួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**២.១. មុខងារនីតិកម្ម**

-ប្រជុំពិនិត្យ និងឆ្លងឯកសារស្តីពី " សេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ "

-ប្រជុំអំពីគំពោងសហការរៀបចំសិក្ខាសាលាស្តីពី " ហេតុផលនាំឲ្យមានការលំបាកក្នុងការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ "

**២.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន០៩ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន២៨ករណី តំកល់ទុកមិនចាត់ការចំនួន០៥ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន៣៥ករណី ព្រមទាំងបានឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០៥ករណី

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ស្តីពី " ការត្រៀមចុះបេសកកម្មតាមដានលទ្ធផលវេទិកាស្តីពី ព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងអង្គការAPI ដើម្បីត្រៀមរៀបចំវគ្គបណ្តុះបណ្តាលជូនក្រុមប្រឹក្សាឃុំ-សង្កាត់

-ប្រជុំជាមួយតំណាងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពី កម្ពុជា ដើម្បីពិភាក្សាលើការអនុវត្ត និងតាមដានយន្តការធ្វើការរួមគ្នា ដើម្បីកំណែទម្រង់ប្រកបដោយប្រសិទ្ធភាពលើអភិបាលកិច្ចល្អក្នុងវិស័យដីធ្លី និងធនធានធម្មជាតិ

-ប្រជុំពិភាក្សាអំពី "ការត្រៀមរៀបចំគណៈប្រតិភូអន្តរគណៈកម្មការ ទៅធ្វើទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍" នៅសាធារណរដ្ឋប្រជាមានិតចិន

-វេទិកាថ្នាក់ស្រុកស្តីពី "ការជំរុញការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រនៅឃុំ/សង្កាត់"

-ចូលរួមសិក្ខាសាលាការិយាល័យ នៃការអនុវត្តអនុសញ្ញាស្តីពី "ការត្រួតពិនិត្យថ្នាំជក់"

-ចូលរួមសិក្ខាសាលាស្តីពី " ទស្សនភូមិសាស្ត្រនយោបាយ និងវិស័យការទូតសភា "

-ចូលរួមស្តាប់ការសន្ទនាជាភាសាបារាំង ជូនដល់សមាជិកព្រឹទ្ធសភា និងមន្ត្រីផ្នែកហ្វ្រង់កូហ្វូនី បង្រៀនដោយលោកសាស្ត្រាចារ្យ Francois Daniel ALBEROLA សាស្ត្រាចារ្យផ្នែកទស្សនវិទ្យា និងអក្សរសាស្ត្រភាសាបារាំង

-រៀបចំបទបង្ហាញស្តីពី " ការប្រែក្លាយការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សអន្តរជាតិទៅជាការអនុវត្តជាក់ស្តែងនៅតាមបណ្តាប្រទេសនានា ការចូលរួមរបស់សភាក្នុងការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សសហប្រជាជាតិ"

-ជួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ (ខាងត្បូង) ដើម្បីស្នើសុំឲ្យជួយសម្របសម្រួលទៅសភានៃសាធារណរដ្ឋកូរ៉េ ក្នុងការផ្តល់ឱកាសទៅបំពេញទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍

-ជួបពិភាក្សាការងារជាមួយលោកស្រី Barbara Lochbihler ជាសមាជិកគណបក្សបៃតង នៃប្រទេសអាល្លឺម៉ង់ ជាអនុប្រធានគណៈកម្មការសិទ្ធិមនុស្ស និងជាសមាជិកនៃក្រុមអាស៊ាននៅសភាអឺរ៉ុប អំពីបញ្ហាការជួញដូរមនុស្ស សិទ្ធិស្ត្រី និងបញ្ហាដីធ្លី នៅកម្ពុជា

-ជួបពិភាក្សាការងារជាមួយលោកលេខាទី១ នៃស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា ស្តីពីដំណើរទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍របស់គណៈកម្មការទី៤ព្រឹទ្ធសភា នៅគណៈបញ្ជាការសន្តិសុខជាតិ TAY NGUYEN នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ជួបពិភាក្សាការងារជាមួយទីប្រឹក្សាគម្រោង GIZ គាំទ្រស្ថាប័នសវនកម្មកំពូល នៃប្រទេសអាស៊ាន (GIZ-ASEANSA) ដើម្បីពិនិត្យ និងពិភាក្សាអំពីគម្រោងរៀបចំកិច្ចប្រជុំពិភាក្សាអំពី " ទ្រឹស្តីនៃពន្ធ"

-ជួបពិភាក្សាការងារជាមួយខេត្ត និងមន្ទីរពាក់ព័ន្ធ ដើម្បីស្តាប់ព័ត៌មាន អំពីបញ្ហាប្រឈម

នានា និងបញ្ហាតម្លៃកសិផល

-ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ស្តីពីការងារវិមជ្ឈការ វិសហមជ្ឈការ និងសេវាសាធារណៈ

-អនុញ្ញាតឲ្យលោក **ដារ៉ារិទ្ធ គឹមយាត** ចូលជួបពិភាក្សាការងារស្តីពី " ការត្រៀមរៀបចំសន្និសីទស្តីអំពី ទស្សនភូមិសាស្ត្រនយោបាយតំបន់ និងវិស័យការទូតសភា "

-អនុញ្ញាតឲ្យគណៈប្រតិភូជប៉ុន ដឹកនាំដោយលោក Takashi Fujihashi អគ្គនាយកក្រុមហ៊ុន Fujihashi Shoten ដែលជាក្រុមហ៊ុនរកស៊ីផ្នែកកសិកម្ម ចូលជួបពិភាក្សាការងារ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ៩០លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១៩លើក ។

**៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ប៊ូ ថង** បានអញ្ជើញធ្វើទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ នៅបញ្ជាការសន្តិសុខជាតិTAY NGUYEN នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-ឯកឧត្តម **យ៉ង់ សែម** បានអញ្ជើញចូលរួមសន្និសីទស្តីពី "ការប្រែក្លាយការប្តេជ្ញាចិត្តផ្នែកសិទ្ធិមនុស្សអន្តរជាតិទៅជាការអនុវត្តជាក់ស្តែង នៅតាមបណ្តាប្រទេសនានា ការចូលរួមរបស់សភាក្នុងការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សសហប្រជាជាតិ " នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ចូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ